# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**

លេខ ៣០៨៩ ព.ណ.ករ.ស

ថ្ងៃច័ន្ទ ១១កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០២៣

## ជម្រាបមក
### លោក/លោកស្រីប្រធានក្រុមហ៊ុន ស៊ាង យី ប៊ីនឡាង ត្រេឌីង ឯ.ក

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលគ្រាប់ពូជរុក្ខជាតិ ខ្សាច់ក្រអូប(ទុកដាក់សំរាម) សម្រាប់សត្វចិញ្ចឹម បន្លែស្រស់ ផ្លែឈើស្រស់ សត្វរស់ ដើមឈើរស់ គ្រាប់ធញ្ញជាតិដែលមិនទាន់កែច្នៃ និងផលិតផលកែច្នៃ គ្រាប់បន្លែដែលអាចរក្សាទុក អាហារដែលមានមូលដ្ឋានពីសាច់ ត្រី ផ្លែឈើ ចាហួយ ស៊ុត ផ្លែឈើគ្រីស្តាល់ និងតៅហ៊ូម៉ាក KOUWEIWANG 口味王 របស់ក្រុមហ៊ុន **ស៊ាង យី ប៊ីនឡាង ត្រេឌីង ឯ.ក** ក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោង:**
- មាត្រា ៣ និងមាត្រា ១១នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតស្នើសុំរបស់ក្រុមហ៊ុន **ស៊ាង យី ប៊ីនឡាង ត្រេឌីង ឯ.ក** ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០២៣
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន HUNAN KOUWEIWANG GROUP CO., LTD. ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០២៣
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី M/១៤៧៥៩៤៣/២០ ជំពូក ២៩ និង ៣១ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០២០។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលគ្រាប់ពូជរុក្ខជាតិ ខ្សាច់ក្រអូប(ទុកដាក់សំរាម) សម្រាប់សត្វចិញ្ចឹម បន្លែស្រស់ ផ្លែឈើស្រស់ សត្វរស់ ដើមឈើរស់ គ្រាប់ធញ្ញជាតិដែលមិនទាន់កែច្នៃ និងផលិតផល កែច្នៃ គ្រាប់បន្លែដែលអាចរក្សាទុក អាហារដែលមានមូលដ្ឋានពីសាច់ ត្រី ផ្លែឈើ ចាហួយ ស៊ុត ផ្លែឈើគ្រីស្តាល់ និងតៅហ៊ូពាក់ម៉ាកខាងលើ របស់ក្រុមហ៊ុន **ស៊ាង យី ប៊ីនឡាង ត្រេឌីង ឯ.ក** ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានពីក្រុមហ៊ុន HUNAN KOUWEIWANG GROUP CO., LTD. ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះមានសុពលភាពត្រឹមថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០២៤ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន HUNAN KOUWEIWANG GROUP CO., LTD. ដែលជាម្ចាស់ម៉ាក។

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះអ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា ហើយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក ប្រូជា**

*<u>ចម្លងជូន:</u>*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
- *ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ-កាលប្បវត្តិ*